Mapeo

តាមដាន និងកត់ត្រាពិភពលោក ជុំវិញអ្នក។



Earth Defenders Toolkit

A project of Digital Democracy

www.earthdefenderstoolkit.com

តើMapeoគឺជាអ្វី?

Mapeo ត្រូវបានបង្កើតឡើងសម្រាប់អ្នកការពារដែនដីដើម្បីងាយស្រួលក្នុងការចងក្រងឯកសារព័ត៌មានអំពីសិទ្ធិមនុស្សនិងបរិស្ថាននិងដើម្បីប្រមូលនូវទិន្នន័យអំពីដីធ្លីរបស់ពួកគេ។

វាអាចត្រូវបានប្រើដោយបុគ្គលឬដោយក្រុមបុគ្គលដែលមានបំណងសហការគ្នានិងចែករំលែកគ្នានូវព័ត៌មាន និងជាពិសេសសម្រាប់អ្នកដែលពូកែធ្វើការងារក្នុងបរិយាកាសឬតំបន់ដាច់ស្រយាលនិងមិនមែនតាមអនឡាញ។ វាមានភាពងាយស្រួលក្នុងការប្រើ មិនចំណាយថវិកា និងអាចចូលមើលព័ត៌មានបាន ហើយអាចកំណត់ភាសាក្នុងស្រុកនិងការរៀបចំផ្សេងៗដោយខ្លួនឯងបាន។

កម្មវិធីMapeo Mobile Appត្រូវបានប្រើដើម្បីប្រមូលភស្តុតាងនៅក្នុងសហគមន៍ឬតាមវាល ដើម្បីថតរូបភាព ឬកត់ត្រាដោយប្រើជភីអេសនូវចំណុចទីតាំងសំខាន់ៗ។ ហើយកម្មវិធីMapeo Desktop appត្រូវបានប្រើដើម្បីរៀបចំចាត់ចែងទិន្នន័យដែលប្រមូលបានតាមរយៈទូរស័ព្ទដៃឬជីភីអេស និងដើម្បីគិតស្រមៃពីរូបភាព កែសម្រួល និងបង្កើតរបាយការណ៍សកម្មភាពដែលវាមានភាពលំបាកក្នុងការធ្វើវានៅលើទូរស័ព្ទដៃ។ ឧបករណ៍ទាំងពីរអាចអនុវត្តសម្រាប់គម្រោងជាក្រុមឬជាបុគ្គលបានពីព្រោះអ្នកអាចធ្វើដំណាលភាពទិន្នន័យរវាងឧបករណ៍ទូរស័ព្ទដៃ និងអាចធ្វើដំណាលភាពពីទូរស័ព្ទដៃទៅកាន់កុំព្យូទ័រ និងពីកុំព្យូទ័រទៅកាន់កុំព្យូទ័របានដែរ។

ឧបករណ៍Mapeo ត្រូវបានសហការគ្នារៀបចំនិងបង្កើតឡើងជាមួយនិងសហគមន៍ជនជាតិដើមភាគតិចដែលប្រឈមការគម្រាមកំហែងចំពោះដីធ្លីដូចជាការធ្វើអាជីវកម្មរ៉ែមាសខុសច្បាប់ ការបំពុលដោយសារប្រេង និងការប្រមាញ់ខុសច្បាប់។ វាត្រូវបានបង្កើតឡើងដើម្បីគាំទ្រពួកគេក្នុងការចងក្រងឯកសារសកម្មភាពទាំងនេះដើម្បីធ្វើសកម្មភាពក្នុងសហគមន៍ប្រឆាំងនឹងសកម្មភាពខុសច្បាប់ទាំងនេះ ដើម្បីរាយការទៅកាន់អាជ្ញាធរ រៀបចំដាក់ពាក្យប្តឹង បង្កើតយុទ្ធនាការផ្សព្វផ្សាយ ឬបង្កើតផែនទីដើម្បីទាមទារយកដីមកវិញ។

ឧបករណ៍ Mapeo គឺជាកម្មវិធីមានលក្ខណៈបើកចំហដែលទទួលបានផលប្រយោជន៍តាមរយៈមតិត្រលប់ជាបន្តបន្ទាប់ពីអ្នកប្រើប្រាស់ទាំងឡាយនៅទូទាំងពិភពលោក។ លោកអ្នកអាចផ្តល់មតិឬសំណើរសម្រាប់ការបង្កើតលក្ខណៈពិសេសបន្ទាប់ទៀតសម្រាប់ឧបករណ៍ Mapeo។



សមាជិកនៃក្រុមល្បាតដីធ្លីSinangoe បានប្រើកម្មវិធី Mapeo Mobile ដើម្បីធ្វើផែនទីកំណត់អំពីដែនដីជីដូនជីតារបស់ពួកគេ(ជាមួយនិងAlianza និង Amazon Frontlines)។

មូលហេតុអ្វីដែលធ្វើឲ្យអ្នកចង់ប្រើឧបករណ៍ Mapeo

មានឧបករណ៍និងកម្មវិធីជាច្រើនដែលអាចត្រូវបានប្រើដើម្បីបង្កើតផែនទីឬចងក្រងឯកសារជាព័ត៌មាន។ ទោះបីយ៉ាងណាក៏ដោយ បន្ទាប់ពីបានធ្វើការងារជាមួយនិងអ្នកការពារដែនដីអស់ជាច្រើនឆ្នាំមក ប្រជាធិបតេយ្យឌីជីថល (Digital Democracy)មិនដែលរកឃើញឧបករណ៍ណាមួយដែលត្រូវបានបង្កើតឡើងដើម្បីតម្រូវការនិងអាទិភាពសំខាន់បំផុតសម្រាប់អ្នកការពារដែនដីនោះទេ ដូច្នេះហើយយើងក៏បានសម្រេចចិត្តបង្កើតនូវឧបករណ៍មួយដោយមានកិច្ចសហការជិតស្និទ្ធជាមួយនិងដៃគូក្នុងស្រុករបស់យើង។

ឧបករណ៍ជាច្រើនអាចទាមទារឲ្យមានការប្រើអ៊ីនធើណិតជាញឹកញាប់ដែលវាមិនមានទេនៅក្នុងតំបន់ងាយរងគ្រោះនិងដាច់ស្រយាល។ វាអាចពឹងផ្អែកលើប្រព័ន្ធផ្ទុកព័ត៌មាន(server)កណ្តាលឬអនឡាញដែលទាញយកទិន្នន័យចេញពីដៃរបស់អ្នកនិងចូលទៅក្នុងដៃ/ការិយាល័យនៃក្រុមហ៊ុនសាជីវកម្ម។ វាអាចមានភាពស្មុកស្មាញសម្រាប់តម្រូវការដែលមិនចាំបាច់ ធ្វើឲ្យសមាជិកសហគមន៍ដែលពុំសូវមានបទពិសោធន៍ផ្នែកកុំព្យូទ័រត្រូវបាត់បង់សិទ្ធិអំណាចនិងឃ្លាតឆ្ងាយពីគេ ឬវាអាចធ្វើឲ្យអ្នកត្រូវពឹងផ្អែកលើអ្នកជំនាញខាងក្រៅឬកម្មវិធីដែលមានតម្លៃថ្លៃជំនួសឲ្យការលើកកំពស់ស្វ័យភាពផ្ទាល់ខ្លួនរបស់អ្នក។

ឧបករណ៍ Mapeo ត្រូវបានបង្កើតឡើងដើម្បីដោះស្រាយចំណុចទាំងអស់នេះ។

1. មានភាពសាមញ្ញក្នុងការប្រើនិងរៀនសូត្រ

ឧបករណ៍ Mapeo Mobile ត្រូវបានបង្កើតឡើងដើម្បីងាយស្រួលសិក្សារៀនសូត្រទោះបីជាអ្នកមិនធ្លាប់ប្រើទូរស័ព្ទដៃទំនើបច្រើនពីមុនក៏ដោយ។ វាប្រើនូវរូបនិមិត្តសញ្ញាច្រើនដើម្បីមានភាពងាយស្រួលមើលនិងយល់បានងាយ។ ឧបករណ៍ Mapeo Desktop ទាមទារឲ្យមានជំនាញកុំព្យូទ័រខ្លះៗដែរ ក៏ប៉ុន្តែវាមានអន្តរផ្ទៃ(interface)សាមញ្ញងាយដែលវាមានចំនួនកំណត់នូវលក្ខណៈពិសេសរបស់វា។ មានឧបករណ៍ផ្សេងៗជាច្រើនទៀតដែលអ្នកអាចបញ្ជូនទិន្នន័យរបស់ចេញទៅបានពីឧបករណ៍Mapeoបើសិនជាវាទាមទារឲ្យមានការវិភាគឬកិច្ចការផែនទីដ៏ស្មុគស្មាញនោះ។ ភាពសាមញ្ញនេះជួយគាំទ្រដល់ការចូលរួមនិងភាពជាម្ចាស់កម្មសិទ្ធិរបស់សហគមន៍ទៅលើគម្រោង។

កម្មវិធីបណ្តុះបណ្តាលក្នុងវគ្គដំបូង(first version)នៃMapeo Mobile ជាមួយនិងក្រុមKofan Alianza Ceibo និង Amazon Frontlines នៅក្នុងតំបន់ Sinangoe។

ក្រុមតាមដានដីធ្លីSiona បានប្រើកម្មវិធី Mapeo Mobile នៅក្នុងព្រៃ ដោយមានការគាំទ្រពី Alianza Ceibo និង Amazon Frontlines។

2. ឧបករណ៍Mapeoអាចដំណើរការទៅបានទាំងស្រុងក្នុងទម្រង់បែបមិនមែនអនឡាញ

ឧបករណ៍Mapeo Mobile ចែករំលែកព័ត៌មានតាមរយៈការប្រើបណ្តាញវ៉ាយហ្វាយ(WiFi)រវាងឧបករណ៍ទាំងឡាយ។ ការងារទាំងនេះពឹងផ្អែកលើការប្រើអ៊ិនធើណិត ប៉ុន្តែក៏អាចតម្លើងប្រើបានដោយមិនបាច់មានបណ្តាញអនឡាញបានដែរដោយការប្រើរ៉ៅទ័រ(routers)ចល័តដ៏សាមញ្ញដែលវាអាចដំណើរការជាមួយនិងកុំព្យូទ័រឬអាគុយសាកតូចមួយដែលជាប្រភពសម្រាប់ផ្តល់ថាមពលភ្លើង។ ឧបករណ៍Mapeo Desktop អាចប្រើបណ្តាញដូចគ្នាទាំងនេះដើម្បីចែករំលែកទិន្នន័យ ហើយក៏អាចបញ្ជូនទិន្នន័យចេញទៅកាន់ហ្វាលឯកសារ(files)ដែលអាចត្រូវបានគេចែករំលែកវានៅលើឧបករណ៍ផ្ទុកទិន្នន័យ (USB sticks)បានផងដែរ។

3. ឧបករណ៍Mapeoប្រើប្រាស់នូវប្រព័ន្ធទិន្នន័យចែករំលែកគ្នាទៅវិញទៅមកដោយមិនចាំបាច់ឆ្លងកាត់បណ្តាញកុំព្យូទ័រមេ(centralized server)នោះទេ

នេះមានន័យថាវាពុំមានប្រភពទិន្នន័យមេឬកណ្តាល ដែលវាធ្វើការតភ្ជាប់សមាជិកក្រុមឬឧបករណ៍ទាំងឡាយនោះទេ។ ផ្ទុយទៅវិញសមាជិកគម្រោងទាំងឡាយដែលធ្វើការងារដំណាលភាពជាមួយគ្នាអាចចម្លងទិន្នន័យយកបាននៅលើឧបករណ៍ទូរស័ព្ទដៃរបស់ពួកគេបាន។ វាធ្វើចលនាជុំវិញបណ្តាញគម្រោងនេះ។ អត្ថប្រយោជន៍របស់វាគឺរាល់ទិន្នន័យដែលអ្នកប្រមូលបាននៅលើឧបករណ៍Mapeo Mobile គឺស្ថិតនៅលើទូរស័ព្ទដៃរបស់អ្នក ហើយអ្នកក៏អាចមើលឃើញទិន្នន័យទាំងឡាយដែលត្រូវបានប្រមូលដោយសមាជិកផ្សេងៗទៀតនៅក្នុងក្រុមរបស់អ្នកបានដែរ។ វាគឺជាប្រព័ន្ធផ្ទុកទិន្នន័យមួយដែលពុំសូវមានរចនាសម្ព័ន្ធជាងទិន្នន័យដែលត្រូវបានផ្ទុកនៅខាងក្រៅនៅលើបណ្តាញកុំព្យូទ័រមេឬអនឡាញ(server or online)នោះទេ ហើយវាមានន័យថាសហគមន៍របស់អ្នកអាចរក្សាបានភាពជាម្ចាស់និងការគ្រប់គ្រងទាំងស្រុងបានទៅលើប្រព័ន្ធទិន្នន័យបើសិនជាអ្នកមានបំណង។



ក្រុមតាមដានត្រួតពិនិត្យSiona បានធ្វើដំណាលភាពលើចំណុចទាំងឡាយដែលត្រូវបានប្រមូលតាមរយៈកម្មវិធីMapeo Mobileទៅកាន់ឧបករណ៍Mapeo Desktopត្រលប់ចូលទៅក្នុងភូមិរបស់ពួកគេ(ជាមួយនិងAlianza Ceibo និង Amazon Frontlines)។



4. អាចកែសម្រួលសម្រាប់ខ្លួនឯងបាន

ឧបករណ៍Mapeo app ភាគច្រើនគឺមានលក្ខណៈអាចកែសម្រួលបានដោយខ្លួនឯងទាក់ទងនិងភាសាផែនទី និងព័ត៌មានដែលអ្នកបានប្រមូល។ នៅពេលដែលអ្នកទាញយកវា វានឹងចេញមកជាមួយនិងផែនទីពិភពលោកដែលមិនមែនលក្ខណៈអនឡាញ ហើយនិងការតម្លើងដោយស្វ័ប្រវត្តិដែលអាចប្រើបានភ្លាមៗដើម្បីប្រមូលព័ត៌មានអំពីការគម្រាមកំហែងផ្សេងៗចំពោះដីធ្លីឬសិទ្ធិ។ ឧបករណ៍ Mapeo ត្រូវបានបកប្រែជាភាសាមួយចំនួន រួចហើយ(រួមមានភាសាអង់គ្លេស ប៉កទុយហ្គាល ថៃ ខ្មែរ និងភាសាជាច្រើនទៀត) ហើយអាចត្រូវបានបកប្រែជាភាសាផ្សេងៗទៀតដែរ។

ឧបករណ៍ Mapeo អាចធ្វើការកែសម្រួលដោយខ្លួនឯងបានទៅលើចំណុច៖

- បកប្រែកម្មវិធីទៅជាភាសាក្នុងស្រុករបស់ខ្លួនបានដោយការប្រើឧបករណ៍អនឡាញដែលគេហៅថា Crowdin។
- បង្កើតបញ្ជីឈ្មោះរៀបរាប់ផ្សេងៗផ្ទាល់ខ្លួនដែលអ្នកចង់ប្រមូលព័ត៌មានអំពីវា និងរៀបចំបង្កើតជាបញ្ជីរសំណួរពាក់ព័ន្ធនិងរូបនិម្មិត្តសញ្ញាផ្ទាល់ខ្លួនរបស់អ្នកសម្រាប់វាបានផងដែរ។
- រៀបចំបង្កើតផែនទីដែលមានលក្ខណៈមិនមែនអនឡាញ ឬផែនទី ដែលមានប្រភេទព័ត៌មានឬទិន្នន័យលម្អិតនៅលើផែនទីដើម្បីគាំទ្រដល់ឯកសាររបស់អ្នកបាន។ ឧទាហរណ៍ដូចជាអ្នកប្រហែលជាចង់បានផែនទីផ្កាយរណបលម្អិតមួយ ឬក៏ផែនទីមួយដែលមានដែនកំណត់អំពីការធ្វើសម្បទានរ៉ែនិងប្លង់កម្មសិទ្ធិដីធ្លី ឬផែនទីមួយដែលមានទិន្នន័យអំពីរយៈកំពស់ដើម្បីជួយអ្នករៀបចំផែនការសម្រាប់ការធ្វើដំណើរចុះភូមិឬវាល។





កម្មវិធី Mapeo ត្រូវបានប្រើដើម្បីចងក្រងជាឯកសារនូវសកម្មភាពខុសច្បាប់ទាំងឡាយនៅក្នុងតំបន់អេក្វាទ័រភាគខាងជើង ដោយមានការគាំទ្រពី Alianza Ceibo និង Amazon Frontlines។

កម្មវិធី Mapeo ត្រូវបានប្រើដើម្បីចងក្រងជាឯកសារនូវសកម្មភាពខុសច្បាប់ទាំងឡាយនៅក្នុងតំបន់អេក្វាទ័រភាគខាងជើង ដោយមានការគាំទ្រពី Alianza Ceibo និង Amazon Frontlines។

របៀបដំណើរការនៃការងារ

ឧបករណ៍ Mapeo អាចត្រូវបានប្រើក្នុងលំហូរការងារផ្សេងៗគ្នាជាច្រើនដើម្បីជួយការពារដីធ្លីនិងសិទ្ធិរបស់អ្នក។

ទាញយកនិងតម្លើងកម្មវិធីMapeo

អ្នកអាចប្រើកម្មវិធី Mapeo ជាមួយនិងការរៀបចំកំណត់ដោយស្វ័យប្រវត្តិដែលមានស្រាប់របស់វាបានភ្លាមៗ ឬអ្នកអាចធ្វើការរៀបចំវាដោយការកំណត់ដោយខ្លួនឯងក៏បាននិងតាមរយៈផែនទីដែលមានលក្ខណៈមិនមែនអនឡាញពាក់ព័ន្ធនឹងព័ត៌មានដែលអ្នកចង់ប្រមូល។ ជំហានចុងក្រោយនេះទាមទារនូវចំណេះដឹងបច្ចេកទេសកាន់តែច្រើន ដូច្នេះអ្នកអាចត្រូវការការជួយគាំទ្របើសិនជាអ្នកចង់រៀបចំកំណត់កម្មវិធី Mapeo ដោយខ្លួនឯងបាន។

ប្រមូលទិន្នន័យដោយការប្រើកម្មវិធី Mapeo Mobile

អាស្រ័យលើតម្រូវការនិងកិច្ចការរបស់អ្នក វាអាចពាក់ព័ន្ធនឹងការធ្វើដំណើរចេញទៅកាន់តំបន់ដាច់ស្រយាល ឬចុះតាមទីកន្លែងផ្សេងៗនៅជុំវិញភូមិរបស់អ្នក។ កម្មវិធី Mapeo Mobile អនុញ្ញាតិឲ្យអ្នកធ្វើការកត់ត្រាចំណុចផ្សេងៗបានតាមរយៈជីភីអេសនិងចាត់ជាប្រភេទផ្សេងៗបាន អាចបន្ថែមកំណត់ត្រានិងរូបភាពដែលត្រូវបានផ្សាភ្ជាប់ទៅនឹងចំណុចផ្សេងៗនិងត្រូវបានបោះត្រាជាមួយនិងពេលវេលាកំណត់។ ឧទាហរណ៍ អ្នកអាចប្រមូលព័ត៌មានអំពីការលេចគំពប់ប្រេងដែលរងប៉ះពាល់ទៅដល់ដីធ្លីរបស់អ្នក អាចថតរូបភាពជាភស្តុតាងនិងចងក្រងជាឯកសារនៅពេលហេតុការណ៍លេចគំពប់បានកើតឡើង។ ឬអ្នកអាចប្រើកម្មវិធី Mapeo ដើម្បីធ្វើផែនទីកំណត់អំពីទីតាំងសំខាន់ៗនៅក្នុងដែនដីរបស់អ្នក ដូចជាតំបន់ប្រមាញ់សត្វ ចងក្រងជាឯកសារអំពីនរណាខ្លះបានប្រើប្រាស់វាហើយរកឃើញសត្វពាហនៈអ្វីខ្លះនៅទីនោះ ឬតំបន់ទាំងឡាយណាដែលមានសារៈសំខាន់ផ្នែកប្រវត្តិសាស្រ្តនិងសាសនា។



Capture the GPS location



Take Pictures



Choose a category and add text details

ធ្វើដំណាលភាពអំពីទិន្នន័យរបស់អ្នក

អ្នកអាចចែករំលែកទិន្នន័យជាមួយនិងសមាជិកក្រុមរបស់អ្នក ដោយការប្រើទូរស័ព្ទដៃរបស់អ្នក ឬក៏ភ្ជាប់ទៅនឹងឧបករណ៍ Mapeo Desktop ហើយបញ្ជូនទិន្ន័យរបស់អ្នកទាំអស់ទៅកាន់ទីនោះបាន។



កែសម្រួល គិតស្រមៃរូបភាព និងវិភាគ

និងវិភាគប្រើឧបករណ៍ Mapeo Desktop ដើម្បីកែសម្រួលនិងពិនិត្យមើលទិន្នន័យដែលអ្នកប្រមូលបានដោយការប្រើកម្មវិធី Mapeo Mobile។ អ្នកអាចធ្វើការកំណត់ទិន្នន័យដើម្បីជួយឲ្យអ្នកគិតស្រមៃដល់រូបភាពអំពីអ្វីដែលនឹងកើតឡើង និងធ្វើការវិភាគអំពីព័ត៌មាននិន្នាការ។





បញ្ជូនទិន្នន័យរបស់អ្នកចេញ

តាមរយៈឧបករណ៍ Mapeo Desktop អ្នកអាចបង្កើតជារបាយការណ៍pdfឬព្រីនបានដោយសាមញ្ញដើម្បីចែករំលែកជាមួយនិងមនុស្សផ្សេងៗទៀតបាន។ អ្នកក៏អាចបង្កើតសំណុំឯកសារ(file)ដើម្បីដាក់បញ្ចូលទិន្នន័យផែនទីវិបសាយបានដ៏សាមញ្ញសម្រាប់ធ្វើការចែករំលែកតាមអនឡាញ។ ទិន្នន័យក៏អាចត្រូវបានទាញយកចេញជាទម្រង់GeoJSON CSV ឬ Shapefile ដើម្បីយកទៅប្រើក្នុងប្រព័ន្ធទិន្នន័យភូមិសាស្ត្រនិងឧបករណ៍វិភាគទិន្នន័យផ្សេងៗបាន។ តាមរយៈកម្មវិធី Mapeo Mobile អ្នកអាចចែករំលែកទិន្នន័យ រូបភាពពាក់ព័ន្ធ និងកំណត់ត្រាតែមួយបានជាមួយនិងមនុស្សផ្សេងៗទៀតតាមរយៈការប្រើអ៊ីម៉េលឬកម្មវិធីWhatsappបើសិនជាវាមានសកម្មភាពចាំបាច់បន្ទាន់ឬបើសិនជាអ្នកមិនអាចប្រើឧបករណ៍ Mapeo Desktop បាន។

របៀបចាប់ផ្តើម

របៀបងាយបំផុតក្នុងការចាប់ផ្តើមប្រើកម្មវិធីMapeoដើម្បីធ្វើផែនទីឬតាមដានកិច្ចការគឺត្រូវទាញយកកម្មវិធី Mapeo Mobile ពី Google Play Storeរួចហើយអាចដំណើរការវាបានហើយ។ យើងសង្ឃឹមថាវាមានភាពងាយស្រួលក្នុងការប្រើប្រាស់ ក៏ប៉ុន្តែនេះគឺជាសៀវភៅគោលសម្រាប់ជាជំនួយផងដែរដើម្បីបង្ហាញផ្លូវអ្នកនិងរបៀបក្នុងការបំពេញកិច្ចការនេះជាក្រុម។ បើសិនជាអ្នកចង់ប្រើវាជាមួយនិងកម្មវិធីMapeo Desktop ឬក៏ប្រើកម្មវិធីDesktop versionដោយខ្លួនឯងដើម្បីធ្វើផែនទី អ្នកអាចទាញយកកម្មវិធីMapeo Desktop ពីវិបសាយរបស់យើងបានហើយអាចរៀនពីរបៀបក្នុងការប្រើប្រាស់វាតាមរយៈសេចក្តីណែនាំនេះ។ មានចំណុចខ្លះមិនទាន់ត្រូវបានបង្ហាញនៅក្នុងសេចក្តីណែនាំនេះនៅឡើយទេ ដូច្នេះបើសិនមានអ្វីមិនច្បាស់ចូរសាកសួរសហគមន៍អ្នកប្រើប្រាស់របស់យើង។

អ្នកក៏អាចស្វែងរកព័ត៌មាននៅទីនេះបានផងដែរ បើសិនជាអ្នកមានបំណងកំណត់ការតម្លើងដោយខ្លួនឯងសម្រាប់កម្មវិធីMapeoជាមួយនិងរូបនិមិត្តសញ្ញាផ្ទាល់ខ្លួននិងផែនទីដែលមានលក្ខណៈមិនមែនអនឡាញនិងមានជំនាញបច្ចេកទេសឬការគាំទ្រដើម្បីធ្វើដូច្នេះ។

យើងចង់ស្តាប់លឺអំពីគម្រោងការងាររបស់អ្នក ហើយសង្ឃឹមថាអ្នកនឹងប្រើកម្មវិធីMapeoដោយរីករាយ។ ចូរចុះឈ្មោះក្នុងបញ្ជីឈ្មោះកម្មវិធីMapeoរបស់យើង បើសិនអ្នកចង់ទទួលបានព័ត៌មានបច្ចុប្បន្នភាពអំពីដំណឹងនិងការអភិវឌ្ឍផ្សេងៗ។

ក្រុមផលិតផែនទីWaorani មកពីAlianza Ceibo បានប្រើកម្មវិធីMapeo Desktop ដើម្បីពិនិត្យមើលព័ត៌មានលម្អិតនៃផែនទីជាមួយនិងប្រជាជននៅក្នុងភូមិ(ជាមួយនិង Alianza និង Amazon Frontlines)។

ឧទាហរណ៍អំពីរបៀបប្រើប្រាស់កម្មវិធីMapeo

ការតាមដានត្រួតពិនិត្យលើបរិស្ថាននៅក្នុងប្រទេសប៉េរូ

សហគមន៍ជនជាតិដើមភាគតិចធ្វើការតាមដានលើការបំពេញការងារក្នុងECA-Amarakaeriនៅក្នុងប្រទេសប៉េរូភាគអាគ្នេយ៍ដែលកំពុងតែប្រើប្រាស់កម្មវិធីMapeo Mobile និងDesktop ជាផ្នែកមួយនៃកម្មវិធីសហការគ្រប់គ្រងទៅលើតំបន់អភិរក្ស។ សហការរួមគ្នាជាមួយនិងអ្នកអភិរក្សសួនឧទ្យាន ពួកគេបានប្រមូលទិន្នន័យអំពីការធ្វើអាជីវកម្មរ៉ែខុសច្បាប់និងផលប៉ះពាល់ផ្សេងៗទៅលើអាងស្តុកទឹកសហគមន៍Amarakaeri និងប្រើប្រាស់វាសម្រាប់ធ្វើសេចក្តីសម្រេចចិត្តនិងធ្វើសកម្មភាពផ្ទៃក្នុងព្រមទាំងធ្វើការចែករំលែកជាមួយនិងអាជ្ញាធរអំពីអំពើខុសច្បាប់ទាំងឡាយដែលត្រូវប្រឈមដោះស្រាយ។

ការផលិតផែនទីដែនដីនៅក្នុងប្រទេសកេនយ៉ា

ប្រជាជន<1>ជនជាតិដើមភាគតិចOgiekនៃតំបន់Mount Elgonកំពុងតែប្រើកម្មវិធីMapeo Mobile និងDesktopដើម្បីធ្វើផែនទីកំណត់តំបន់សំខាន់ៗ</1>នៅលើដីធ្លីរបស់ពួកគេដែលជាផ្នែកមួយនៃការទាមទារដីធ្លីជាប្រវត្តិសាស្ត្រ។

ជីដូនជីតាការផលិតផែនទីនៅក្នុងប្រទេសអេក្វាទ័រ

ប្រជាជនSiekopaiនៃប្រទេសអេក្វាទ័រភាគខាងជើងបានប្រើកម្មវិធីMapeo Desktopនៅក្នុងភូមិរបស់ពួកគេដើម្បីស្វែងរករូបភាពផ្កាយរណបនៃដែនដីជីដូនជីតារបស់ពួកគេជាមួយនិងជនចាស់ជរានិងធ្វើការចងក្រងសាច់រឿងជាឯកសារទាក់ទងនឹងបឹងទន្លេនិងការតាំងលំនៅរស់នៅបែបបុរាណ។

កម្មវិធី Mapeo ត្រូវបានប្រើដើម្បីចងក្រងជាឯកសារនូវសកម្មភាពខុសច្បាប់ទាំងឡាយនៅក្នុងតំបន់អេក្វាទ័រភាគខាងជើង ដោយមានការគាំទ្រពី Alianza Ceibo និង Amazon Frontlines។

ក្រុម Siekopai នៅក្នុងតំបន់អេក្វាទ័រភាគខាងជើងបានប្រើកម្មវិធីMapeo ដើម្បីប្រមូលចំណេះដឹងពីជនចាស់ជរាមុនពេលធ្វើផែនទីកំណត់អំពីដែនដីដូនតារបស់ពួកគេនៅក្នុងតំបន់Lagarto Cocha (ជាមួយនិង Alianza Ceibo និងAmazon Frontlines)។

ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយសម្រាប់ប្រជាជនងាយរងគ្រោះដោយសារតែអាកាសធាតុនៅក្នុងប្រទេសថៃ៖ អ្នកស្ម័គ្រចិត្តសុខាភិបាលភូមិនៅក្នុងប្រទេសថៃតំបន់ឆ្នេរសមុទ្រកំពុងតែ

ប្រើកម្មវិធីMapeoដើម្បីប្រមូលទិន្នន័យអំពីជនងាយរងគ្រោះ ដើម្បីធានាបានថាពួកគេអាចទទួលបានជំនួយចំគោលដៅនិងភ្លាមៗក្នុងករណីមានគ្រោះមហន្តរាយធម្មជាតិកើតឡើង

លក្ខណៈពិសេស

តម្រូវការកម្មវិធី(Software)
ឧបករណ៍Mapeo Desktopអាចត្រូវបានតម្លើងនៅលើកុំព្យូទ័រ(PC) Mac និង Linuxបាន។
កម្មវិធីMapeo Mobile បច្ចុប្បន្នអាចដំណើរការនៅលើប្រព័ន្ធAndroidបាន។

សុវត្ថិភាព
ទិន្នន័យដែលប្រមូលបានតាមរយៈកម្មវិធីMapeo Mobile គឺមិនអាចត្រូវបានគេកែនិងត្រូវបានចងកូដដើម្បីធានាថាវាមិនត្រូវបានគេកែឬធ្វើឲ្យខូចបានឡើយ។ រាល់ទិន្នន័យទាំងអស់ មិនថាវាត្រូវបានបង្កើតនៅលើឧបករណ៍ Mapeo Desktop ឬ Mapeo Mobileនោះទេ វាត្រូវបានបំលែងទៅជាកូដដែលអាចត្រូវបានធ្វើការផ្ទៀងផ្ទាត់ដើម្បីភាពត្រឹមត្រូវរបស់វា។ គម្រោងឯកជនទាំងឡាយអាចត្រូវបានបង្កើតឡើងដោយការប្រើសោរសុវត្ថិភាពដែលធ្វើការកំណត់ថានរណាអាចធ្វើដំណាលភាពទិន្នន័យជាមួយវាបាន។

លក្ខណៈពិសេសសំខាន់ៗ
បំពេញមុខងារបានទាំងស្រុងដោយមិនប្រើអនឡាញ។ ទិន្នន័យមិនត្រូវបានផ្ទុកក្នុងប្រព័ន្ធមេ ផែនទីនិងការរៀបចំកំណត់ខ្លួនឯងបាន ធ្វើដំណាលភាពពីមួយទៅមួយបាន

ភាសា
អាចបកប្រែជាភាសាផ្សេងៗបាន។ បច្ចុប្បន្នមានបកប្រែជាភាសាដូចជា ភាសាភូមា នីដឺឡែន អង់គ្លេស បារាំង អាឡាម៉ង់ ហ៊ីនឌី ឥណ្ឌូនេស៊ី ខ្មែរ ម៉ាឡេស៊ី ណេប៉ាល់ ប៉ទុយហ្គាល់ អេស្ប៉ាញ ស្វាហ៊ីលី ថៃ និងវៀតណាម។

ប្រព័ន្ធផ្សព្វផ្សាយ
អាចដាក់បន្ថែមរូបភាពបាន។

ជម្រើសនៃការបញ្ចូល
អាចបញ្ចូលទីតាំងជីភីអេសនិងសំណុំឯកសាររូបភាពផ្សេងៗ(shapefile)ចូលទៅក្នុងកម្មវិធី Mapeo Deskktop បាន។

ជម្រើសនៃការបញ្ជូនចេញ
កម្មវិធីMapeo Desktopអាចធ្វើចេញជាទម្រង់pdf ព្រីនជារបាយការណ៍ GeoJSON CSV ឬជាទម្រង់Shapefile។ កម្មវិធី Mapeo Mobileអាចបញ្ជូនចេញចំណុចតែមួយទៅកាន់អ៊ីម៉េល កម្មវិធីWhatsapp និងកម្មវិធីចែករំលែកតាមរយៈទូរស័ព្ទដៃផ្សេងៗបាន។

ប្រជាធិបតេយ្យឌីជីថល(Digital Democracy)សូមថ្លែងអំណរគុណចំពោះសហគមន៍ជនជាតិដើមភាគតិចទាំងអស់ដែលបានចូលរួមពាក់ព័ន្ធក្នុងការបង្កើតកម្មវិធីMapeo Mobile និង Desktop។

Earth Defenders Toolkit

A project of Digital Democracy

www.earthdefenderstoolkit.com